អ អ ក

EAC

**អាជ្ញាធរអគ្គិសនីកម្ពុជា**

លេខ ០៧០-សរ១៧អអក

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

ភ្នំពេញ, ថ្ងៃទី ២៧ ខែ កុម្ភៈ ឆ្នាំ២០១៧

# លិខិតអនុញ្ញាត

## អាជ្ញាធរអគ្គិសនីកម្ពុជា

- អនុវត្តតាមការកំណត់របស់ច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឲ្យប្រើដោយព្រះរាជក្រម លេខនស/រកម/០២០១/០៣ ចុះថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០០១
- អនុវត្តតាមការកំណត់របស់អនុក្រឹត្យ លេខ៥៤.អនក្រ.បក ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០០៥ ស្តីពីគោលការណ៍វាយតម្លៃភាពត្រឹមត្រូវនៃចំណាយក្នុងអាជីវកម្មអគ្គិសនី
- អាជ្ញាបណ្ណរួមលេខ១៦៣.អ ចេញឲ្យលោក កង ឈី នៅថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០០៧
- យោងសេចក្តីសម្រេចស្តីពីការកែសម្រួលបញ្ជីថ្លៃលក់អគ្គិសនី តាមយន្តការកែតម្រូវថ្លៃលក់តាមថ្លៃប្រេងម៉ាស៊ូតរបស់អាជ្ញាធរអគ្គិសនីកម្ពុជាលេខ៤៩៧.សរ-១៦-អអក ចុះថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០១៦
- យោងតាមតម្លៃប្រេងម៉ាស៊ូតលើទីផ្សារ ក្នុងខែមករា ឆ្នាំ២០១៧
- យោងតាមចំណារឯកភាពលើកំណត់បង្ហាញរបស់នាយកដ្ឋានបញ្ជីថ្លៃលក់ និងត្រួតពិនិត្យគណនេយ្យសេវាកម្ម លេខ០០៦-១៧-បថល ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ២០១៧

## អនុញ្ញាត

**ប្រការ ១** -

ផ្អែកតាមតារាងថ្លៃលក់អគ្គិសនីថ្មីនៅក្នុងប្រការ១ នៃសេចក្តីសម្រេច របស់អាជ្ញាធរអគ្គិសនីកម្ពុជា លេខ៤៩៧.សរ-១៦-អអក ចុះថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០១៦ និងផ្អែកលើមូលដ្ឋានថ្លៃប្រេងម៉ាស៊ូតនៅលើទីផ្សារជាមធ្យមនៅក្នុងខែមករា ឆ្នាំ២០១៧ មានតម្លៃស្មើនឹង ៧២៤ (ប្រាំពីររយម្ភៃបួន) ដុល្លារអាមេរិកក្នុង១តោន អាជ្ញាធរអគ្គិសនីកម្ពុជាសម្រេចអនុញ្ញាតឲ្យសេវាករ កង ឈី អ្នកកាន់អាជ្ញាបណ្ណលេខ១៦៣.អ ធ្វើសេវាកម្មផ្គត់ផ្គង់អគ្គិសនីឲ្យអ្នកប្រើប្រាស់ទូទៅ នៅទីរួមស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ អនុវត្តអត្រាថ្លៃលក់ស្មើនឹង ២,០៥០(ពីរពាន់ហាសិប) រៀលក្នុង១គីឡូវ៉ាត់ម៉ោង ។

**ប្រការ ២ -**

អត្រាថ្លៃលក់អគ្គិសនីថ្មីខាងលើនេះ ត្រូវបានអនុញ្ញាតឲ្យអនុវត្តចំពោះការចេញ"វិក្កយបត្រថ្លៃអគ្គិសនី" ចាប់ពីថ្ងៃទី២៥ខែកុម្ភៈ ឆ្នាំ២០១៧តទៅរហូតដល់មានការអនុញ្ញាតជាថ្មីដោយអាជ្ញាធរអគ្គិសនីកម្ពុជាទៅ តាមកម្រិតថ្លៃប្រេងម៉ាស៊ូតលើទីផ្សារ ។ អ្នកកាន់អាជ្ញាបណ្ណមិនត្រូវផ្លាស់ប្តូរខួប និងពេលវេលាក្នុងការ កត់ត្រាលេខអំណាននាឡិកាស្ទង់ កាលបរិច្ឆេទនៃការចេញវិក្កយបត្រថ្លៃអគ្គិសនី និងការបែងចែកក្រុម អតិថិជនទេ ក្នុងការអនុវត្តអត្រាថ្លៃលក់អគ្គិសនីថ្មីខាងលើ។ បញ្ជីថ្លៃលក់អគ្គិសនីចាស់ ដែលបានដាក់ឲ្យ ប្រើប្រាស់ត្រូវចាត់ទុកជានិរាករណ៍ចាប់ពីពេលអនុវត្តបញ្ជីថ្លៃលក់អគ្គិសនីថ្មីនេះ ។

**ប្រការ ៣ -**

ការអនុវត្តអត្រាថ្លៃលក់អគ្គិសនីនេះ មានប្រសិទ្ធភាពអនុវត្តចំពោះអ្នកប្រើប្រាស់អគ្គិសនីដែលឋិតនៅ ក្នុងតំបន់ចែកចាយរបស់សេវាករ កង ឈី ប៉ុណ្ណោះ ។

**ប្រការ ៤ -**

សេវាករ កង ឈី មានភារកិច្ចផ្សព្វផ្សាយអំពីការអនុញ្ញាតនេះ ដល់អតិថិជនរបស់ខ្លួនគ្រប់ប្រភេទ ដែលពាក់ព័ន្ធ ។

**អាជ្ញាធរអគ្គិសនីកម្ពុជា**

**ប្រធាន**

**បណ្ឌិត.ធី នរិន្ទ**

<u>ចម្លងជូនៈ</u>

- ក្រសួង រ៉ែ និងថាមពល
- សាលាខេត្តឧត្តរមានជ័យ
- មន្ទីរ រ៉ែ និងថាមពល ខេត្តឧត្តរមានជ័យ
- សាលាឃុំបាក់អន្លង់, សាលាឃុំផ្អាវ, សាលាឃុំអូរស្វាយ សាលាឃុំទំនប់ដាច់, សាលាឃុំត្រពាំង
  "ដើម្បីជូនជ្រាប"
- សេវាករ កង ឈី
  "ដើម្បីផ្សព្វផ្សាយ និងអនុវត្ត"
- ឯកសារ-កាលប្បវត្តិ